CDRI ជាវិទ្យាស្ថានកម្ពុជា ឯករាជ្យឈានមុខ
សំរាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

សង្ខេបសំរាប់
គោលនយោបាយ

ឆ្នាំ ២០១១ លេខ ០២

# គណនេយ្យភាពក្នុងប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិកម្ពុជា

*ដោយ ប៉ក់ គឹមជឿន[១]*

## ១. សេចក្តីផ្តើម

វិមជ្ឈការ និងវិសហមជ្ឈការគឺជាកំណែទម្រង់ធំមួយដែលកំពុងដំណើរការនៅកម្ពុជា ដោយមានការបោះឆ្នោតជាសកល នៅថ្នាក់ឃុំ/សង្កាត់នៅឆ្នាំ២០០២ និង២០០៧ និងការបោះឆ្នោតជាអសកលនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅខែឧសភា ២០០៩ កន្លងមក ។ ក្រោយពីការបង្កើតក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ជំហានបន្ទាប់គឺត្រូវធ្វើការផ្ទេរមុខងារ និងធនធាន ដើម្បីឱ្យថ្នាក់នេះមានលទ្ធភាពឆ្លើយតបចំពោះតម្រូវការក្នុងមូលដ្ឋានរបស់ខ្លួន ។

ការផ្ទេរមុខងារ និងធនធានទៅឱ្យថ្នាក់ក្រោមជាតិ ជាដំណើរការមួយដែលត្រូវអនុវត្តតាមលក្ខណៈជាប្រព័ន្ធ និងតាមលំដាប់លំដោយ ។ កិច្ចការសំខាន់មួយនៅក្នុងដំណើរការនេះ គឺការបង្កើត និងពង្រឹងគណនេយ្យភាពក្នុងការគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិ ។ មន្ត្រីជាន់ខ្ពស់ម្នាក់នៃរដ្ឋាភិបាលកម្ពុជា បានលើកបញ្ជាក់ថា គណនេយ្យភាពគឺជាឆ្អឹងខ្នងនៃអភិបាលកិច្ចល្អ ជាពិសេសក្នុងការគ្រប់គ្រងចំណាយសាធារណៈ[២] ។

អត្ថបទនេះពិភាក្សាអំពីគណនេយ្យភាពនៅក្នុងប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈ នៅថ្នាក់ក្រោមជាតិរបស់កម្ពុជា និងអំពីការងារកំណែទម្រង់ដែលរដ្ឋាភិបាលកំពុងអនុវត្ត ដើម្បីពង្រឹងគណនេយ្យភាពនេះ ។ ជាដំបូង អត្ថបទមានពិភាក្សាពីនិយមន័យ និងខ្លឹមសារនៃពាក្យគណនេយ្យភាព ក្នុងបរិបទនៃការងារគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិ បន្ទាប់មកឆ្លុះបញ្ចាំងទ្រឹស្តីទាំងនោះមកក្នុងករណីនៅកម្ពុជា[៣] ។ ប្រធានបទនេះ បើរៀបរាប់លម្អិត គឺមានលក្ខណៈស្មុគស្មាញច្រើន ប៉ុន្តែការបកស្រាយនៅពេលនេះ ផ្តោតតែលើទិដ្ឋភាពរួម និងចំណុចគោលៗងាយយល់ ដើម្បីផ្តល់ជាជំនួយស្មារតីប៉ុណ្ណោះ ។

## ២. ទ្រឹស្តីជាសកលស្តីពីគណនេយ្យភាពនៅក្នុងការគ្រប់គ្រងចំណាយសាធារណៈ

គណនេយ្យភាព ជាធាតុមួយសំខាន់នៅក្នុងអភិបាលកិច្ចល្អ ។ ពាក្យនេះ ផ្តោតន័យលើទិដ្ឋភាពសំខាន់ ២៖ (១) នៅពេលមានការប្រគល់សិទ្ធិ និងធនធានឲ្យជនណាម្នាក់ ឬស្ថាប័នណាមួយហើយ ជននោះ ឬស្ថាប័ននោះ ត្រូវមានគណនេយ្យភាពលើការប្រើប្រាស់សិទ្ធិ និងធនធានដែលប្រគល់ឱ្យនោះ និង (២) ប្រព័ន្ធអភិបាលកិច្ច និងគ្រប់គ្រងត្រូវតែបង្កើតឡើង ដើម្បីតម្រូវឱ្យជននោះ ឬស្ថាប័ននោះ មានគណនេយ្យភាព ទោះចង់ ឬមិនចង់ក្តី (Pak *et al.* 2007) ។

ក្នុងទិដ្ឋភាពទីមួយ គណនេយ្យភាព គឺជាទំនាក់ទំនងរវាងតួអង្គពីរ ដោយម្នាក់ជាអ្នកត្រូវមានគណនេយ្យភាពចំពោះម្នាក់ទៀត លើការប្រើប្រាស់សិទ្ធិនិងធនធានដែលខ្លួនទទួលបាន ។ មានសំណួរ២ ដែលគួរចោទសួរ៖ (១) តើអ្នកណាត្រូវមានគណនេយ្យភាព ចំពោះអ្នកណា? និង (២) តើត្រូវមានគណនេយ្យភាពលើបញ្ហាអ្វី? សំណួរទាំងពីរនេះ ហាក់ដូចជាសាមញ្ញ ប៉ុន្តែនៅពេលគេដាក់អនុវត្តឱ្យមានគណនេយ្យភាព ឧបសគ្គភាគច្រើននឹងកើតមានឡើង ។

ទ្រឹស្តីជាច្រើនបានលើកពីកត្តាដ៏ចាំបាច់ៗ ដើម្បីធានាឱ្យមានគណនេយ្យភាព ។ របាយការណ៍អភិវឌ្ឍន៍ពិភពលោក (WDR) ឆ្នាំ២០០៤ បានលើកថា ដើម្បីសម្រេចបានគណនេយ្យភាព ត្រូវមានធាតុសំខាន់ៗចំនួន ៥៖ (១) ការធ្វើប្រតិភូកម្ម (២) ការប្រគល់ធនធាន (៣) ការអនុវត្តការងារ (៤) ព័ត៌មានអំពីការអនុវត្តការងារ និង (៥) ការផ្តល់រង្វាន់ ឬដាក់ទោសទណ្ឌ ទៅតាមលទ្ធផលការងារ ។ តាមទ្រឹស្តីនេះ ជាឧទាហរណ៍ ប្រសិនបើលោក

---

១ ប៉ក់ គឹមជឿន ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន វបសអ ។

២ ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្នុងសុន្ទរកថា នាឱកាសបើកសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ភ្នំពេញ ថ្ងៃទី៦-៧ តុលា ២០០៩ ។

៣ អត្ថបទនេះ មួយផ្នែកផ្អែកតាម របាយការណ៍លេខ ៣៨ របស់ CDRI មានចំណងជើងថា គណនេយ្យភាពក្នុងការគ្រប់គ្រងចំណាយសាធារណៈនៅក្នុងការងារវិមជ្ឈការនៅកម្ពុជា ដែលបោះពុម្ពផ្សាយនៅឆ្នាំ២០០៨ និងរៀបរៀងដោយលោក ប៉ក់ គឹមជឿន និង David Craig ។

សុខ ត្រូវមានគណនេយ្យភាពលើការងារអ្វីមួយ ទីមួយ គាត់ត្រូវទទួលការផ្ទេរមុខងារ និងការទទួលខុសត្រូវច្បាស់លាស់ និងការផ្ទេរធនធានសមស្រប ។ លោក សុខ ខ្លួនឯងក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញការងារនោះដែរ ។ ចំណែកឯស្ថាប័ន ឬបុគ្គល ដែលទាមទារគណនេយ្យភាពពីលោក សុខ ក៏ត្រូវ ទី១ មានព័ត៌មានអំពីអ្វីដែលលោក សុខ បានធ្វើ និង ទី២ បើគាត់ធ្វើបានល្អ គួរមានការផ្ដល់រង្វាន់ តែបើមិនបានល្អ ត្រូវមានការដាក់ទោសទណ្ឌតាមទម្ងន់ទោស (World Bank 2004) ។

ក្នុងវិស័យសាធារណៈ ទំនាក់ទំនងគណនេយ្យភាពស្មុគស្មាញខ្លាំង ព្រោះមានតួអង្គច្រើនដែលទាក់ទងគ្នាបំពេញការងារច្រើនមុខ និងពាក់ព័ន្ធគ្នា ។ ដូច្នេះ ដើម្បីធានាឱ្យមានគណនេយ្យភាព ត្រូវតែមើលឲ្យហួសពីទំនាក់រវាងរវាងតួអង្គនិងតួអង្គ ហើយផ្ដោតលើការបង្កើតប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចមួយ ដើម្បីធានាថា ធាតុផ្សំដ៏សំខាន់ៗនៃគណនេយ្យភាពគឺអាចបង្កើតឡើង និងដាក់អនុវត្តបានជាក់ស្ដែង ។

ការគ្រប់គ្រងចំណាយសាធារណៈ សំដៅដល់ (១) ការបែងចែក និង (២) ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នូវធនធានសាធារណៈដែលទទួលបានពីគ្រប់ប្រភព (Schiavo-Campo and Tommasi 1999) ។ ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈ រួមមាន រចនាសម្ព័ន្ធគ្រប់គ្រង ច្បាប់ និងនីតិវិធីជាប់ពាក់ព័ន្ធទាំងឡាយ រាប់តាំងពី ការធ្វើផែនការ ការកសាងថវិកា ការអនុវត្តថវិការហូតដល់ ការត្រួតពិនិត្យ និងវាយតម្លៃការធ្វើចំណាយ ។ នៅក្នុងប្រព័ន្ធនេះ រាល់បុគ្គលនិងស្ថាប័នដែលទទួលបានធនធានសាធារណៈនិងសិទ្ធិក្នុងការបែងចែកនិងប្រើប្រាស់ធនធានទាំងនោះ គឺត្រូវមានគណនេយ្យភាព ។

គណនេយ្យភាពក្នុងចំណាយសាធារណៈ មាន ២ ប្រភេទ៖ (១) គណនេយ្យភាពចំពោះការអនុលោមតាមច្បាប់ និងវិធានជាធរមានក្នុងការគ្រប់គ្រងចំណាយសាធារណៈ (ហៅដោយខ្លីថា គណនេយ្យភាពចំពោះអនុលោមភាព) និង (២) គណនេយ្យភាពចំពោះលទ្ធផលសម្រេចបានពីការចំណាយធនធាននោះ (ហៅដោយខ្លីថា គណនេយ្យភាពចំពោះលទ្ធផល) ។ គណនេយ្យភាពទាំង ២ ប្រភេទនេះ ជាទូទៅបំពេញឱ្យគ្នាទៅវិញទៅមក តែពេលខ្លះក៏អាចប្រទាំងប្រទើសគ្នាដែរ ។ ឧទាហរណ៍ ក្នុងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចកំណត់នូវវិធានដ៏តឹងរ៉ឹងសម្រាប់ការអនុវត្តច្បាប់ថវិកា ។ ភាពតឹងរ៉ឹងនេះ អាចជួយធានាគណនេយ្យភាពចំពោះអនុលោមភាព ។ ប៉ុន្តែវាក៏អាចបណ្ដាលឱ្យក្រសួង-ស្ថាប័នចំណាយ បាត់បង់លទ្ធភាពបត់បែនក្នុងការបែងចែក និងប្រើប្រាស់ចំណាយ្យ សមស្របតាមកាលៈទេសៈជាក់ស្ដែង ហើយក៏មិនអាចសម្រេចលទ្ធផលការងារបានល្អ ។ ប៉ុន្តែភាពធូររលុងពេក ក៏អាចនាំឱ្យមានការធ្វេសប្រហែសការប្រើប្រាស់ធនធានរដ្ឋមិនបានត្រឹមត្រូវ និងអំពើពុករលួយ ដែលធ្វើឱ្យគេមិនអាចសម្រេចបានទាំងគណនេយ្យភាពចំពោះអនុលោមភាព និងគណនេយ្យភាព ចំពោះលទ្ធផល ។ ដូច្នេះ ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈដែលល្អ ត្រូវកំណត់ និងរក្សាឱ្យបាននូវតុល្យភាពរវាងភាពរឹងត្អឹង និងភាពបត់បែន ។

នៅក្នុងប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ ថវិការដ្ឋមួយភាគបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ក្នុងស្ថានភាពនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានទាំងគណនេយ្យភាពចំពោះអនុលោមភាព និងគណនេយ្យភាពចំពោះលទ្ធផល ព្រោះពួកគេជាអាណាប័ក[៤] មួយ ដែលមានតួនាទី និងសិទ្ធិអំណាច ក្នុងការអនុញ្ញាតឱ្យមានការចំណាយ គឺដូចគ្នានឹងក្រសួង/មន្ទីរផ្សេងៗដែរ ។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាព ចំពោះស្ថាប័នគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារជាតិ) និងចំពោះរដ្ឋសភាជាតិ ដែលគេហៅថា គណនេយ្យភាពទៅថ្នាក់លើ ។

វិមជ្ឈការ មិនមែនគ្រាន់តែជាការទម្លាក់ធនធានទៅឱ្យថ្នាក់ក្រោមជាតិប៉ុណ្ណោះទេ ប៉ុន្តែវាជាកំណែទម្រង់មានលក្ខណៈនយោបាយដែលសំដៅ បង្វិតរដ្ឋាភិបាលឱ្យទៅជិតនឹងប្រជាជន ។ បើតាមទ្រឹស្ដី ការធ្វើបែបនេះ ជួយពង្រឹងគណនេយ្យភាពនយោបាយ រវាងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងប្រជាជននៅមូលដ្ឋាន ទៅលើការងារអភិវឌ្ឍដែលសម្រេចបាន និងតម្លាភាពក្នុងការបែងចែក និងប្រើប្រាស់ ធនធានរបស់រដ្ឋ ។ លក្ខណៈនេះ ហៅថា គណនេយ្យភាពទៅថ្នាក់ក្រោម ។

ក្រុមប្រឹក្សា មិនអាចធ្វើការងារដោយផ្ទាល់ ដើម្បីបំពេញតម្រូវការរបស់ប្រជាជនបានទេ គឺត្រូវមានប្រព័ន្ធរដ្ឋបាល និងមន្ត្រីប្រតិបត្តិដែលមានសមត្ថភាព និងការទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តរាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ។ មន្ត្រីប្រតិបត្តិត្រូវទទួលបានការផ្ទេរមុខងារពីក្រុមប្រឹក្សា ព្រមទាំង ធនធាននិងសិទ្ធិដ៏ចាំបាច់សម្រាប់គ្រប់គ្រង និងចាត់ចែងមុខងារទាំងនោះ ។ ក្នុងន័យនេះ មន្ត្រីប្រតិបត្តិ ត្រូវតែមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាទៅលើអនុលោមភាព និងលទ្ធផលទាក់ទងនឹងការប្រើប្រាស់សិទ្ធិ និងធនធាន ។ លក្ខណៈនេះ ហៅថា គណនេយ្យភាពតាមខ្សែទទឹង ។

ជាសង្ខេប នៅក្នុងប្រព័ន្ធវិមជ្ឈការ ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈ ត្រូវជម្រុញឱ្យមានគណនេយ្យភាពសំខាន់ ៣៖ (១) រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ (ទៅថ្នាក់លើ) (២) រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និង

[៤] អាណាប័កសំដៅដល់អ្នកមានសិទ្ធិអនុញ្ញាតឱ្យធ្វើចំណាយ ។

ដ្យាក្រាមបង្ហាញពីគណនេយ្យភាពនៅក្នុងការគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិ៖




ប្រជាជន (ទៅថ្នាក់ក្រោម) និង (៣) រវាងក្រុមប្រឹក្សា និងមន្ត្រីប្រតិបត្តិនៅថ្នាក់ក្រោមជាតិ (ខ្សែទទឹង) ។ ដើម្បីធានាឱ្យមានគណនេយ្យភាពទាំងនេះ ត្រូវបង្កើត និងពង្រឹងជាប្រចាំនូវ ប្រព័ន្ធអភិបាលកិច្ចសមស្របមួយ (World Bank 2005) ។ ប៉ុន្តែករណីនៅកម្ពុជា បង្ហាញច្បាស់ថា ការកសាងប្រព័ន្ធអភិបាលកិច្ចបែបនេះ ជាការងារលំបាក និងត្រូវការរយៈពេលវែង ។

## ៣. បរិបទសម្រាប់ការស្វែងយល់ពីការគ្រប់គ្រងចំណាយសាធារណៈនៅកម្ពុជា

ជាគោលនយោបាយ គណនេយ្យភាពដែលរដ្ឋាភិបាលកម្ពុជា ចង់បាននៅក្នុងប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិ គឺមិនខុសគ្នាអ្វីច្រើនពីក្នុងទ្រឹស្តីដែលទើបបានបកស្រាយនោះទេ ។ មន្ត្រីជាន់ខ្ពស់ម្នាក់នៃរដ្ឋាភិបាលកម្ពុជា បានលើកបញ្ជាក់ថា យើងត្រូវមានទាំង គណនេយ្យភាពចំពោះអនុលោមភាព (ដែលលោកហៅថា គណនេយ្យភាពហិរញ្ញវត្ថុ) គណនេយ្យភាពចំពោះប្រជាជន និងគណនេយ្យភាពចំពោះក្រុមប្រឹក្សា ។ ប៉ុន្តែបញ្ហាលំបាកនិងត្រូវការពេលវេលាច្រើន គឺ ការបង្កើត និងពង្រឹងប្រព័ន្ធអភិបាលកិច្ចមួយ ដែលអាចសម្រេចបានគណនេយ្យភាពទាំង ៣ នេះ (សូមមើលកំណត់បញ្ជាក់លេខ ២) ។

មុននឹងឈានដល់ការពិភាក្សាអំពី ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈ នៅថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន គួរពិនិត្យពីបរិបទសំខាន់ៗមួយចំនួនសិន ។

បរិបទទី១៖ ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈដូចមានសព្វថ្ងៃ គឺជាលទ្ធផលនៃការធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទម្រង់វិមជ្ឈការ ដែលបន្តមកតាំងពីឆ្នាំ១៩៩៣ ។ ពីដំបូង គឺការធ្វើមជ្ឈការហិរញ្ញវត្ថុនៅឆ្នាំ១៩៩៣ ដែលពេលនោះ មានការកាត់បន្ថយសិទ្ធិអំណាចថវិកាមួយផ្នែកធំរបស់ថ្នាក់ខេត្ត ស្រុក និងឃុំ ។ នៅឆ្នាំ១៩៩៤ និងបន្ទាប់មកនៅឆ្នាំ១៩៩៨ សិទ្ធិអំណាចថវិកាមួយចំនួនបានប្រគល់ឱ្យទៅថ្នាក់ខេត្តវិញ ។ ក្នុងពេលជាមួយគ្នាក៏មានការធ្វើវិសហមជ្ឈការតាមវិស័យដូចជាកម្មវិធីអាទិភាពដែលចាប់ផ្តើមនៅឆ្នាំ២០០០ នៅក្នុងវិស័យអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ជាដើម ដើម្បីផ្ទេរថវិកាឱ្យបានលឿន និងទៀងទាត់ទៅឱ្យអ្នកផ្តល់សេវានៅមូលដ្ឋាន (Pak and Craig 2008) ។

បរិបទទី២៖ ប្រព័ន្ធថវិកាជាតិបច្ចុប្បន្នរបស់កម្ពុជា បានបែងចែកជាច់រវាងចំណាយចរន្ត និងចំណាយមូលធន ។ ចំណាយចរន្តសំដៅដល់ រាល់ការចំណាយដែលកើតមានជាប្រចាំ ដូចជា ប្រាក់បៀវត្សរ៍ ចំណាយទិញសម្ភារៈការិយាល័យ ។ល។ ចំណាយមូលធន គឺជាចំណាយត្រូវចាត់ចូលក្នុងគម្រោងវិនិយោគ ៣ឆ្នាំរំកិល ដែលរៀបចំឡើងដោយក្រសួង/មន្ទីរ ហើយបូកសរុបដោយក្រសួងផែនការជារៀងរាល់ឆ្នាំ ។ ដោយសារចំណូលក្នុងស្រុកនៅមិនទាន់ប្រមូលបានធំទូលាយ រដ្ឋាភិបាលកន្លងមកមានលទ្ធភាពរ៉ាប់រងតែលើបន្ទុកចំណាយចរន្ត ហើយមួយផ្នែកធំនៃចំណាយមូលធន ត្រូវពឹងផ្អែកលើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ។ ជាឧទាហរណ៍ ក្នុងច្បាប់ថវិកាឆ្នាំ២០១០ ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ មានប្រមាណ ៦៥% នៃចំណាយមូលធនសរុបដែលមានទំហំដល់ទៅ ៣១២១ ពាន់លានរៀល (RGC 2009) ។

ទោះបីជាមានការខិតខំប្រឹងប្រែងធ្វើសុខដុមនីយកម្មហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ ជាមួយនឹងប្រព័ន្ធគ្រប់គ្រងថវិកាជាតិក្តី ក៏មួយផ្នែកធំនៃហិរញ្ញប្បទានទាំងនោះ នៅតែបង្ហូរក្រៅប្រព័ន្ធរតនាគារជាតិ ហើយអនុវត្តនៅក្នុងរាប់រយអង្គភាពគ្រប់គ្រងគម្រោងរបស់ពួកគេ ។ នៅឆ្នាំ២០១០ ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍មានចំនួន ២៣៦៤ពាន់លានរៀល ក្នុងនោះ មានតែ ១៥,៤% ប៉ុណ្ណោះ ដែលផ្តល់ឱ្យក្នុងរូបភាពជាមូលនិធិទ្រទ្រង់ថវិកា និងបង្ហូរតាមប្រព័ន្ធរតនាគារ ។ ដៃគូអភិវឌ្ឍន៍កន្លងមកក៏បានផ្ទេរជំនួយរបស់ខ្លួនតាមរយៈអង្គការមិនមែនរដ្ឋាភិបាលដែរ ដើម្បីឱ្យពួកគេផ្តល់សេវាដោយផ្ទាល់ដល់សហគមន៍ ។

បរិបទទី៣៖ ក្នុងកំណែទម្រង់វិមជ្ឈការដែលបានអនុវត្តជាបន្តតាំងពីឆ្នាំ២០០២ មក រដ្ឋាភិបាលមានមូលនិធិឃុំ/សង្កាត់ ដែលជាមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ និងទទួលបានហិរញ្ញប្បទានពីរដ្ឋាភិបាលផង និងពីដៃគូអភិវឌ្ឍន៍ផង ។ លើសពីនេះទៀត រដ្ឋាភិបាលក៏បង្កើតកម្មវិធីសាកល្បងមួយចំនួន ដើម្បីជម្រុញឱ្យថ្នាក់ខេត្ត/ស្រុកមានសកម្មភាពចូលរួមក្នុងការងារវិមជ្ឈការ ។ ការគ្រប់គ្រងមូលនិធិឃុំ/សង្កាត់ និងមូលនិធិសម្រាប់ថ្នាក់ខេត្ត/ស្រុកទាំងនេះ អនុវត្តតាមប្រព័ន្ធចំណាយមួយផ្សេងពីប្រព័ន្ធគ្រប់គ្រងចំណាយទូទៅរបស់ជាតិ ក្នុងបំណងដើម្បីពន្លឿនការបង្ហូរមូលនិធិ និងបញ្ចៀសហានិភ័យហិរញ្ញវត្ថុ ។ ប្រព័ន្ធដោយឡែកនេះ បានដាក់អនុវត្តក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យហៅកាត់ថា គ.ជ.អ.ប (NCDD 2008) ។

ជាសង្ខេប មានប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈយ៉ាងហោចចំនួន៣ ដែលកំពុងដំណើរការនាបច្ចុប្បន្ន គឺ (១) ប្រព័ន្ធទូទៅរបស់ជាតិ (២) ប្រព័ន្ធរបស់ដៃគូអភិវឌ្ឍន៍ និង (៣) ប្រព័ន្ធរបស់មូលនិធិឃុំសង្កាត់ និងកម្មវិធីសាកល្បងតាមបែបវិមជ្ឈការ នៅក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប ។ គួរកត់សំគាល់ដែរថា ប្រព័ន្ធទាំង៣ បានផ្តើមឡើងដោយឡែកពីគ្នា និងខ្វះសុខដុមនីយកម្មជាមួយគ្នា ។ ធ្វើដូច្នេះមិនមែនត្រឹមតែ បង្កើតឱ្យមានគណនេយ្យភាពខុសៗគ្នាប៉ុណ្ណោះទេ ប៉ុន្តែអាចប្រទាំងប្រទើសគ្នាទៀតផង ។ ផ្នែកខាងក្រោមមានពិភាក្សាជាលម្អិតអំពីប្រព័ន្ធទាំង ៣ ។

## ៤. ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិ

### *៤.១. ប្រព័ន្ធទូទៅរបស់ជាតិ*

ប្រព័ន្ធនេះផ្អែកតាមច្បាប់គ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ១៩៩៣ និង ២០០៨ ។ នៅថ្នាក់ក្រោមជាតិ ប្រព័ន្ធនេះអនុវត្តលើ (១) ថវិការបស់រដ្ឋបាលថ្នាក់ខេត្ត[៥] (ពីមុនហៅថា សាលាខេត្ត ឬសាលាក្រុង) និង (២) ថវិការបស់មន្ទីរជំនាញ ។ បច្ចុប្បន្នដោយសារច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅមិនទាន់បានអនុម័ត ការគ្រប់គ្រងថវិការបស់ខេត្តនៅបន្តប្រើច្បាប់ឆ្នាំ១៩៩៨ ។ តាមច្បាប់នេះ ខេត្តជាអាណាប័កដើមខ្សែសម្រាប់ថវិកាខេត្ត និងជាអាណាប័កផ្ទេរសិទ្ធិសម្រាប់ថវិការបស់មន្ទីរ ។ ចំពោះក្រុមប្រឹក្សាស្រុក/ក្រុង[៦] ដែលមិនទាន់មានប្រព័ន្ធគ្រប់គ្រងថវិកា ថ្នាក់នេះនៅតែបន្តទទួលថវិការបស់ខ្លួនតាមរយៈថវិកាខេត្ត ។ មានចំណុចកែប្រែមួយគឺក្នុងថវិកាខេត្តសព្វថ្ងៃ មានចែងច្បាស់ពីចំនួនថវិការបស់ស្រុក/ក្រុង ដែលពីមុនមកពុំមានការចែងបែបនេះទេ ។

ក្នុងច្បាប់ថវិកាជាតិប្រចាំឆ្នាំ ខ្ទង់ថវិកាខេត្តមានចុះបញ្ជាក់ទាំងខាងចំណូល និងចំណាយ ។ ជាទូទៅ ចំណូលដែលខេត្តគ្រោងប្រមូលបាន មានបរិមាណតិចជាងចំណាយគ្រោងទុក ហើយឱនភាពត្រូវបំពេញដោយឧបត្ថម្ភធនពីថវិការដ្ឋ ។ រដ្ឋបាលថ្នាក់ខេត្ត មានទាំងចំណាយចរន្ត និងចំណាយមូលធន ។ នៅឆ្នាំ២០១០ ថវិកាខេត្ត មានដល់ ៣២៦,៣៧ពាន់លានរៀល ដោយក្នុងនេះ ប្រហែល ៧៧,៧៣ពាន់លានរៀលជាចំណាយមូលធន ។ វាតំណាងឲ្យ ៣,៩៣% នៃចំណាយសរុបរបស់ជាតិដែលមាន ៨៣០០ពាន់លានរៀល និងកើនខ្ពស់ជាងថវិកាខេត្តឆ្នាំ២០០៩ ដល់ ១,១% មួយភាគធំ ដោយសារចំណាយបៀវត្សរ៍ សម្រាប់សមាជិកក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខ័ណ្ឌដែលទើបជាប់ឆ្នោត (RGC 2009) ។

ច្បាប់ថវិកាជាតិប្រចាំឆ្នាំ ក៏មានបង្ហាញផងដែរនូវថវិការបស់មន្ទីរដែលមានតែចំណាយចរន្ត និងគ្មានចំណាយមូលធនទេ ។ ក្នុងថវិកាជាតិឆ្នាំ២០១០ ថវិការបស់មន្ទីរមានដល់ ១២០៩,៤៣ពាន់លានរៀល ឬ ១៤,៥៧% នៃចំណាយជាតិសរុប ។ តាមច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ ថវិការបស់មន្ទីរ គឺជាថវិការបស់ក្រសួង ប៉ុន្តែនៅពេលអនុវត្តថវិកា ក្រសួងត្រូវផ្ទេរសិទ្ធិទៅឱ្យអភិបាលខេត្តធ្វើជាអាណាប័កក្នុងការធ្វើចំណាយរបស់មន្ទីរ ។

ក្នុងប្រព័ន្ធគ្រប់គ្រងចំណាយទូទៅរបស់ជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (តាមរយៈ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) និងរតនាគារជាតិ (តាមរយៈ រតនាគារខេត្ត) ដើរតួនាទីសំខាន់ជាអ្នកត្រួតពិនិត្យ និងជាគណនេយ្យករសាធារណៈ ។ ដោយសារប្រព័ន្ធនេះ នៅទន់ខ្សោយ រដ្ឋាភិបាលយកចិត្តទុកដាក់ជាដំបូង លើគណនេយ្យភាពចំពោះអនុលោមភាពក្នុងការបែងចែក និងប្រើប្រាស់ចំណាយ ជាជាងលើគណនេយ្យភាពលើលទ្ធផល ។ របាយការណ៍ស្តីពី កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បង្ហាញថា នាបច្ចុប្បន្ន សូម្បីតែការធានាឱ្យបាននូវគណនេយ្យភាពលើអនុលោមភាព ក៏មានការលំបាកដែរ ។ ដូច្នេះ រដ្ឋាភិបាលនៅត្រូវការពេលវេលាច្រើនទៀត ទម្រាំតែការពង្រឹងគណនេយ្យភាពចំពោះលទ្ធផល អាចចេញជាផ្លែផ្កា ។

ការផ្តោតខ្លាំងពេកទៅលើអនុលោមភាព ក្នុងពេលដែលប្រព័ន្ធគ្រប់គ្រងនៅមិនទាន់រឹងមាំ វានាំឱ្យមានភាពរឹងត្អឹងជ្រុល ពន្យឺតដល់ដំណើរការអនុវត្តថវិកា និងបង្កើនហានិភ័យដល់ថវិការបស់ជាតិ (World Bank & Asian Development Bank 2003) ។ ទាក់ទងនឹងបញ្ហានេះ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ (២០០៤-២០០៨) បានខិតខំសម្រួល និងធ្វើឱ្យការអនុវត្តថវិកាមានបែបបទសាមញ្ញ សំដៅជួយឱ្យទឹកប្រាក់អាចហូរបានទាន់ពេល និងទៀងទាត់ ហើយក៏ទទួលបានលទ្ធផលល្អក្នុងពេលកន្លងមក ។ ថ្មីៗនេះ ការប្រើប្រាស់ប្រព័ន្ធធនាគារ អេស៊ីលីដា ក្នុងការផ្ទេរប្រាក់បៀវត្សរ៍ (ដំបូង ធ្វើនៅខេត្តបន្ទាយមានជ័យ និងខេត្តកណ្តាល) កាន់តែធ្វើឱ្យការអនុវត្តថវិកាមានភាពរលូន ។ រតនាគារជាតិកំពុងពិចារណាពង្រីកការប្រើប្រព័ន្ធធនាគារ អេស៊ីលីដា នេះ នៅ ៩ ខេត្តផ្សេងទៀត (National Treasury 2010; PFMRP 2009) ។

ដើម្បីបង្កើនគណនេយ្យភាពចំពោះលទ្ធផល មានការអនុញ្ញាតឲ្យអង្គភាពចំណាយ អាចបត់បែនបានច្រើនជាងមុនក្នុងការបែងចែក និងប្រើប្រាស់ចំណាយ ឱ្យស្របតាមស្ថានភាពជាក់ស្តែង ។ ឧទាហរណ៍ កន្លងមក មានការដាក់ឱ្យប្រើថវិកាកម្មវិធីនៅក្នុង ៨ វិស័យអាទិភាព មានជាអាទិ៍ វិស័យ អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ ។ល។ ថវិកាតាមកម្មវិធី ត្រូវកសាងឡើង ដោយភ្ជាប់គម្រោង

[៥] ក្នុងអត្ថបទនេះ ពាក្យថ្នាក់ខេត្តមានរួមបញ្ចូលទាំងរាជធានីផងដែរ លើកលែងតែមានការបញ្ជាក់ផ្សេង ។

[៦] ក្នុងអត្ថបទនេះ ពាក្យថ្នាក់ស្រុក/ក្រុង មានរួមបញ្ចូលទាំងខ័ណ្ឌផងដែរ លើកលែងតែមានការបញ្ជាក់ផ្សេង ។

ចំណាយ ជាមួយនឹងលទ្ធផលរំពឹងទុក និងមានសូចនាករសម្រាប់វាស់វែងជាក់លាក់ ។ ស្ថាប័នចំណាយអាចបត់បែនបានច្រើនក្នុងការចាយថវិកាតាមកម្មវិធី ដូច្នេះ អាចជាជំហានល្អមួយឆ្ពោះទៅរកគណនេយ្យភាពចំពោះលទ្ធផល។ ប៉ុន្តែនាពេលបច្ចុប្បន្ន ថវិកានេះមានចំនួនតិចនៅឡើយ ។ ក្នុងឆ្នាំ២០១០ ថវិកាតាមកម្មវិធី មានចំនួន ២៥៥,៩៤ពាន់លានរៀល ឬ ៥,១% នៃថវិកាចរន្តសរុបរបស់ជាតិ ។ ម៉្យាងទៀត ថវិកាតាមកម្មវិធីមួយភាគធំ បានដាក់អនុវត្តតែនៅតាមក្រសួង លើកលែងតែនៅក្នុងវិស័យអប់រំ និងសុខាភិបាលដែលមានថវិកាតាមកម្មវិធីមួយភាគ បានបែងចែកទៅឲ្យអ្នកផ្ដល់សេវា នៅជួរមុខរួចហើយ (Pak 2009a; Pak 2009b) ។

ទាក់ទិននឹងគណនេយ្យភាពតាមខ្សែទទឹង សព្វថ្ងៃប្រព័ន្ធគ្រប់គ្រងទូទៅនៅថ្នាក់ក្រោមជាតិ នៅមានកម្រិតនៅឡើយ ។ អភិបាលខេត្ត មានងារជាអាណាប័កផ្ទេរសិទ្ធិក៏ពិតមែន តែមានសិទ្ធិតិចតួចលើការបែងចែក និងប្រើប្រាស់ចំណាយរបស់មន្ទីរ ដោយសារសិទ្ធិទាំងនេះជាដែនសមត្ថកិច្ចរបស់មន្ទីរហិរញ្ញវត្ថុ និងរតនាគារខេត្ត ។ ម៉្យាងទៀត សព្វថ្ងៃ ស្ទើរតែគ្មានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលក្នុងការឃ្លាំមើលការគ្រប់គ្រងថវិការដ្ឋទេ លើកលែងតែក្នុងវិស័យសុខាភិបាល ដែលមានការចូលរួមពីអង្គការជាដៃគូក្នុងការពិនិត្យពីដំណើរការអនុវត្តថវិការបស់មន្ទីរសុខាភិបាល ។

ជាសង្ខេប ប្រព័ន្ធគ្រប់គ្រងចំណាយទូទៅនៅថ្នាក់ក្រោមជាតិ ផ្ដោតជាសំខាន់លើ គណនេយ្យភាពចំពោះអនុលោមភាព ។ វាជាប្រព័ន្ធមានលក្ខណៈមជ្ឈការខ្លាំង ដោយក្នុងនោះ ថវិកាជាតិតែប្រមាណ ១៨,៥% ប៉ុណ្ណោះ ដែលត្រូវបានទម្លាក់ទៅដល់ថ្នាក់ក្រោមជាតិ ហើយមន្ទីរហិរញ្ញវត្ថុខេត្ត និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងរតនាគារខេត្ត និងរតនាគារជាតិ ដើរតួសំខាន់នៅក្នុងប្រព័ន្ធនេះ ។ រដ្ឋាភិបាល ត្រូវបន្តអនុវត្តកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ជាពិសេសក្នុងដំណាក់កាលទី២ នេះ ដែលជាដំណាក់កាលផ្ដោតលើការពង្រឹងគណនេយ្យភាពរបស់អង្គភាពចំណាយ ។

### ៤.២. ប្រព័ន្ធគ្រប់គ្រងចំណាយក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប

គ.ជ.អ.ប ជាយន្តការអន្តរក្រសួងមួយ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨ ដើម្បីដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ ។ បន្ថែមពីលើការងារផ្នែកគោលនយោបាយ គ.ជ.អ.ប មានតួនាទីរៀបចំ និងអនុវត្តគម្រោងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលរួមមាន ថវិកាឃុំ/សង្កាត់ និងមូលនិធិនានាសម្រាប់គាំទ្រដល់ថ្នាក់ខេត្ត ស្រុក/ក្រុង ។ ថវិកាប្រចាំឆ្នាំនេះ ទទួលបានហិរញ្ញប្បទានពីថវិការដ្ឋ និងពីការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ (NCDD 2008) ។ ថវិកាប្រចាំឆ្នាំ២០១០ មានចំនួនសរុប ៣៨១,៣ពាន់លានរៀល ក្នុងនេះប្រហែល ៤០% ទទួលមកពីរដ្ឋាភិបាល ក្រៅពីនោះមកពីដៃគូអភិវឌ្ឍន៍ (សូមមើលកំណត់បញ្ជាក់លេខ២) ហើយប្រហែល ២៩១,១ពាន់លានរៀល បានគ្រោងសម្រាប់ចំណាយនៅថ្នាក់ក្រោមជាតិ ។ ថវិកាប្រមាណ ១៩៥ពាន់លានរៀល បានផ្ទេរទៅឲ្យថ្នាក់ឃុំ/សង្កាត់ ដោយបែងចែកជាពីរចំណែក៖ ១៤៩ពាន់លានរៀលសម្រាប់មូលនិធិឃុំ/សង្កាត់ និង ៤៦ពាន់លានរៀល សម្រាប់ប្រើជាមូលនិធិមានភ្ជាប់លក្ខខណ្ឌ ដែលត្រូវចំណាយលើសកម្មភាពបានកំណត់ឱ្យជាមុន ដោយដៃគូអភិវឌ្ឍន៍ចំនួន ១០ ។ ការបែងចែកមូលនិធិឃុំសង្កាត់ ត្រូវអនុវត្តតាមរូបមន្តដែលផ្អែកលើចំនួនប្រជាជន និងកម្រិតក្រីក្ររបស់មូលដ្ឋាននីមួយៗ ។

នៅក្នុងថវិកាប្រចាំឆ្នាំ មានមូលនិធិវិនិយោគសម្រាប់រាជធានី/ខេត្ត (ហៅកាត់ថា PIF) និងមូលនិធិសម្រាប់ក្រុងស្រុក/ក្រុង (ហៅកាត់ថា DIF) ។ PIF គេបែងចែកទៅឱ្យរាជធានី/ខេត្ត ដោយផ្អែកតាមចំនួនប្រជាជន ។ ការបែងចែក PIF បានប្រកាសផ្សព្វផ្សាយនៅក្នុងសិក្ខាសាលាជាតិស្ដីពីការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ របស់ គ.ជ.អ.ប ។ PIF មួយភាគធំ បានប្រើប្រាស់សម្រាប់អនុវត្តគម្រោងដែលមន្ទីរខេត្តលើកឡើង ដើម្បីបម្រើជាប្រយោជន៍នៅថ្នាក់ឃុំ/សង្កាត់ ។ នៅឆ្នាំ២០០៩ PIF មានចំនួន ២,២៤លានដុល្លារ (ប្រមាណ ៣,២ពាន់លានរៀល) ។ ក្នុងឆ្នាំដូចគ្នា DIF ត្រូវបានបែងចែកទៅឲ្យ ១០៦ស្រុក/ក្រុង ដោយស្រុក/ក្រុងនីមួយៗ ទទួលបាន ៣០.០០០ដុល្លារ (ប្រមាណ ១២៣លានរៀល) សម្រាប់អនុវត្តគម្រោងដែលបម្រើតម្រូវការរបស់ឃុំ/សង្កាត់ ។ តំណាងរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏មានតួនាទីចូលរួមក្នុងការបែងចែក និងប្រើប្រាស់ DIF ផងដែរ (PSDD 2009) ។

នៅថ្នាក់ខេត្ត ភ្នាក់ងារទទួលខុសត្រូវលើការគ្រប់គ្រងចំណាយនៃមូលនិធិខាងលើ គឺ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការប្រតិបត្តិរាជធានី/ខេត្ត (PRDC/ExCom) ដែលគេបានបង្កើតឡើងនៅឆ្នាំ២០០២ នៅក្រោម អតីតកម្មវិធីសិលា និងបន្ទាប់មកផ្ទេរមកក្រោមការគ្រប់គ្រងរបស់ គ.ជ.អ.ប នៅចុងឆ្នាំ២០០៨ ។ ថវិកាប្រចាំក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប គេគ្រប់គ្រងតាមប្រព័ន្ធមួយផ្សេងទៀត ដូចមានចែងក្នុងសៀវភៅណែនាំសម្រាប់ការកសាងផែនការ និងថវិកាសម្រាប់ឃុំ/សង្កាត់ និងវិធានផ្សេងៗទៀត ។ ប្រព័ន្ធនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានទទួលស្គាល់ ប៉ុន្តែវាមានខ្លឹមសារ និងការអនុវត្តខុសគ្នាច្រើនពីប្រព័ន្ធទូទៅរបស់ជាតិ (មានរៀបរាប់ក្នុងផ្នែក ៤.១) ។

ទាក់ទងនឹងគណនេយ្យភាព ប្រព័ន្ធក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប ផ្ដោតជាសំខាន់លើការការពារ និងបញ្ចៀស

ហានិភ័យ ដែលអាចកើតមានលើថវិកាបានគ្រោងឡើង ។ ប្រព័ន្ធនេះ មានលក្ខណៈទំនើប និងការកែលម្អជាប្រចាំ ។ ការត្រួតពិនិត្យ វាយតម្លៃ និងសវនកម្មផ្ទៃក្នុង ដែលធ្វើឡើងដោយ PRDC/ExCom និងសវនកម្មមកពីក្រៅ បានដើរតួនាទីយ៉ាងសំខាន់ ។ ប្រព័ន្ធនេះល្អប្រសើរព្រោះមិនមែនផ្តោតតែលើគណនេយ្យភាពចំពោះអនុលោមភាពប៉ុណ្ណោះទេ ប៉ុន្តែលើលទ្ធផលសម្រេចបាន តាមរយៈគម្រោងអនុវត្តនៅថ្នាក់ឃុំ/សង្កាត់ ខេត្ត និងស្រុក/ក្រុង ផងដែរ ។

ការបង្កើតផែនការសកម្មភាព និងថវិកាប្រចាំ មិនមែនដើម្បីត្រឹមតែការពារធនធានដែលមានប៉ុណ្ណោះទេ ប៉ុន្តែដើម្បីជម្រុញវិមជ្ឈការ និងវិសហមជ្ឈការ និងពង្រឹងគណនេយ្យភាពដល់ប្រជាជននៅមូលដ្ឋានផងដែរ ។ ការជម្រុញឲ្យប្រជាជនចូលរួមចំណែកក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និងការបង្កើតជា យន្តការគណនេយ្យភាពនានានៅមូលដ្ឋាន ជាឧទាហរណ៍ដ៏ល្អនៃការជម្រុញឱ្យមានគណនេយ្យភាពទៅថ្នាក់ក្រោម ។ ការតម្រូវឱ្យមន្ទីរ និងការិយាល័យជំនាញប្រើប្រាស់ PIF និង DIF ដើម្បីឆ្លើយតបនឹងតម្រូវការមូលដ្ឋាន ជាឧទាហរណ៍មួយទៀតនៃគណនេយ្យភាពទៅថ្នាក់ក្រោម ។រីឯការតម្រូវឱ្យមន្ទីរនិងការិយាល័យទាំងនេះ ចុះកិច្ចសន្យាជាមួយ PRDC/ExCom ដើម្បីទទួលបានថវិកាទាំង២ នេះ វាជាឧទាហរណ៍ល្អមួយនៃការជម្រុញគណនេយ្យភាពតាមខ្សែទទឹង នៅថ្នាក់ខេត្ត និងស្រុក/ក្រុង (PSDD 2009) ។

ប្រព័ន្ធគ្រប់គ្រងក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប នៅមានចំណុចខ្វះខាតមួយចំនួន ។ ទី១ ប្រព័ន្ធនេះគ្របដណ្តប់តែលើធនធានប្រមាណ ៤,៦% នៃថវិកាសរុបរបស់ជាតិដែលមានទំហំជិតដល់ ៨៣០០ពាន់លានរៀលនៅឆ្នាំ២០១០។ តួលេខនេះ បង្ហាញថា វិមជ្ឈការនៅកម្ពុជានៅមានកម្រិតទាបក្នុងវិស័យហិរញ្ញវត្ថុ ។ ទី២ ប្រព័ន្ធរបស់ គ.ជ.អ.ប នេះមានការទទួលស្គាល់ពី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមែន ប៉ុន្តែមិនទាន់បានធ្វើសុខដុមនីយកម្ម ជាមួយប្រព័ន្ធទូទៅរបស់ជាតិទេ ។ ឧទាហរណ៍ មូលនិធិឃុំសង្កាត់ត្រូវផ្ទេរតាមរយៈរតនាគារដែរ ប៉ុន្តែដំណើរការកសាងផែនការ និងថវិការបស់វា មានលក្ខណៈខុសប្លែកពីការគ្រោងផែនការ និងថវិការបស់អង្គភាពរដ្ឋជាទូទៅ ។ រដ្ឋាភិបាលបានចាប់ផ្តើមកែប្រែប្រព័ន្ធថវិការបស់ឃុំ/សង្កាត់ ដើម្បីឱ្យមានសង្គតិភាព (ស៊ីគ្នា) ជាមួយនឹងប្រព័ន្ធទូទៅរបស់ជាតិ ដូចជានៅពេលថ្មីៗនេះ គេបានរៀបចំដាក់ឱ្យប្រើប្រាស់ប្លង់គណនេយ្យថ្មីសម្រាប់ឃុំ/សង្កាត់ ដែលស៊ីគ្នាជាមួយនឹងប្លង់គណនេយ្យទូទៅរបស់រដ្ឋ ។ ប៉ុន្តែកិច្ចការទាំងនេះ ទើបចាប់ផ្តើម និងត្រូវបន្តធ្វើជាច្រើនទៀត ។

បន្ថែមពីលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ គ.ជ.អ.ប ក៏បាននិងកំពុងមើលការខុសត្រូវ និងសម្របសម្រួល លើ ២០ គម្រោងផ្សេងទៀតនៅទូទាំងប្រទេសដែលរឹតតែមិនសូវមានសុខដុមនីយកម្មជាមួយប្រព័ន្ធទូទៅរបស់រដ្ឋទៅទៀត ។ឧទាហរណ៍ គម្រោងទាំងនេះមិនធ្វើការផ្ទេរមូលនិធិរបស់ខ្លួនតាមប្រព័ន្ធរតនាគារទេ តែផ្ទេរតាមរយៈគណនីនៅធនាគារឯកជន ទៅឱ្យគោលដៅជាឃុំ/សង្កាត់ ខេត្ត ស្រុក/ក្រុង ។ គម្រោងទាំងនេះ ពឹងផ្អែកលើប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃ និងសវនកម្មផ្ទាល់របស់ដៃគូអភិវឌ្ឍន៍ ដើម្បីបញ្ចៀសហានិភ័យហិរញ្ញវត្ថុ ។

កង្វះខាតនៃការធ្វើសុខដុមនីយកម្ម ទៅក្នុងប្រព័ន្ធទូទៅរបស់ជាតិ បានប៉ះពាល់ដល់ភាពជាម្ចាស់ និងលទ្ធភាពរបស់រដ្ឋាភិបាល ក្នុងការឆ្លើយតបចំពោះប្រជាជន ។ វាជាមូលហេតុមួយដែលនាំឱ្យមន្ត្រីជាប់ឆ្នោត ត្រូវមានគណនេយ្យភាពកម្រិតទាបចំពោះម្ចាស់ឆ្នោត ។ ការដាក់បន្សុំចូលគ្នា និងសុខដុមនីយកម្ម អាចអនុវត្តបានច្រើនទៀត ប៉ុន្តែប្រព័ន្ធគ្រប់គ្រងចំណាយទូទៅរបស់ជាតិ ត្រូវតែមានការកែលម្អ និងមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបញ្ចៀសហានិភ័យហិរញ្ញវត្ថុ ។

ទោះមានបញ្ហាដូចខាងលើក្តី គម្រោងរបស់ដៃគូអភិវឌ្ឍន៍ បានចូលរួមចំណែកជាក់ស្តែងក្នុងការពង្រឹងគណនេយ្យភាពរវាងមន្ត្រីជាប់ឆ្នោត និងម្ចាស់ឆ្នោត ដោយជួយឱ្យម្ចាស់ឆ្នោត មានលទ្ធភាពខ្លាំងជាងមុនក្នុងការទាមទារគណនេយ្យភាពនេះ ។ ឧទាហរណ៍ គម្រោងការពារបរិស្ថាន និងលើកកម្ពស់ជីវិភាពរបស់ ដានីដា បានជម្រុញការផ្តល់អំណាចដល់ប្រជាជន តាមការកសាងសមត្ថភាពរបស់សង្គមស៊ីវិលនៅមូលដ្ឋាន ។ ឧទាហរណ៍មួយទៀត គឺគម្រោងហៅកាត់ថា SPACE នៃសហព័ន្ធអឺរ៉ុប ។

ជាសង្ខេប ប្រព័ន្ធរបស់ គ.ជ.អ.ប មានលក្ខណៈល្អច្រើន ព្រោះផ្តោតទាំងលើគណនេយ្យភាពចំពោះអនុលោមភាព និងលទ្ធផល គណនេយ្យភាពចំពោះប្រជាជន និងគណនេយ្យភាពតាមខ្សែទទឹង ។ ប៉ុន្តែប្រព័ន្ធនេះនៅមានវិសាលភាពតូច ហើយមួយផ្នែកធំអនុវត្តតាមរយៈអង្គភាពគ្រប់គ្រងគម្រោង ។ ទោះយ៉ាងនេះក្តី បទពិសោធន៍ និងមេរៀនដែលបានចងក្រងអំពីប្រព័ន្ធនេះ មានសារៈសំខាន់ជាខ្លាំង ជាពិសេសសម្រាប់ការតាក់តែង និងអនុវត្ត ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## *៤.៣. ប្រព័ន្ធរបស់គម្រោង និងកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍*

គម្រោង និងកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍ បានលើកមកពិភាក្សានៅពេលនេះ ដោយសារជំនួយបរទេសមួយភាគធំបានបង្ហូរទៅឲ្យ និងយកទៅចំណាយនៅថ្នាក់ក្រោមជាតិ។ នៅឆ្នាំ២០០៩ ប្រហែល ៦០% នៃថវិកាជំនួយ បានដកយកទៅចំណាយនៅថ្នាក់ខេត្ត ដោយបានបង្ហូរទៅឲ្យតាមក្រៅប្រព័ន្ធរតនាគារ និងបានអនុវត្តតាមរយៈរាប់រយអង្គភាពគ្រប់គ្រងគម្រោង (RGC 2010) ។

ការពិភាក្សាអំពីជំនួយបរទេសនៅក្នុងអត្ថបទនេះ វាស្មុគស្មាញបន្តិច តែចាំបាច់ ។ បើរាប់ត្រឹមតែគម្រោងដែលជួយដល់កំណែទម្រង់វិមជ្ឈការ សព្វថ្ងៃមាន ២០គម្រោងដៃគូអភិវឌ្ឍន៍ដែលប្រើយន្តការសម្របសម្រួល របស់ គ.ជ.អ.ប ។ ដៃគូអភិវឌ្ឍន៍នានានៅមានគម្រោងជាច្រើនទៀតដែលកំពុងដំណើរការតាមវិស័យជំនាញផ្សេងៗ និងដែលត្រូវមានការផ្លាស់ប្តូរ នៅពេលរដ្ឋាភិបាលចាប់ផ្តើមគិតគូរពីការផ្ទេរមុខងារ និងបន្ទុកចំណាយទៅឱ្យថ្នាក់ក្រោមជាតិ ។ មកទល់បច្ចុប្បន្ន គេបានរៀបចំគម្រោងទាំងនេះ និងអនុវត្តវាក្នុងក្របខ័ណ្ឌនៃក្រសួងជំនាញ ដោយមិនបានគិតពីផលប៉ះពាល់ដល់កំណែទម្រង់វិមជ្ឈការទេ ។ ពួកគេនៅតែផ្តោតលើគណនេយ្យភាពតាមខ្សែបណ្តោយ ក្នុងវិស័យនីមួយៗ ដោយមិនបានគិតពី គណនេយ្យភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាជនឡើយ ។

កន្លងមក វិស័យខ្លះចាប់ផ្តើមគិតគូពីបញ្ហានេះហើយ នៅក្នុងសកម្មភាពផ្តល់សេវារបស់ពួកគេ ។ ឧទាហរណ៍ នៅតាមឃុំ/សង្កាត់ តាមរយៈការប្រជុំប្រចាំខែ ថ្នាក់ដឹកនាំសាលារៀន និងមណ្ឌលសុខភាព បានរាយការណ៍ពីការផ្តល់សេវារបស់អង្គភាពខ្លួន និងទទួលយកយោបល់ពីក្រុមប្រឹក្សា ។ គណៈកម្មាធិការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏បានចូលរួមចំណែកច្រើនដែរនៅក្នុងការងារអប់រំ និងសុខភាពនៅមូលដ្ឋាន (Pak 2010) ។

ក្នុងវិស័យសុខាភិបាល ការសម្របសម្រួលក៏មានធ្វើនៅថ្នាក់ខេត្តដែរ ។ តាមរយៈការប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត មន្ទីរសុខាភិបាល មន្ត្រីតំណាងអភិបាលខេត្ត មន្ត្រីគម្រោង និង NGOs ដែលធ្វើការងារផ្តល់សេវាសុខាភិបាល មកជួបប្រជុំវាយតម្លៃរួមគ្នាលើការងារអនុវត្តបាន និងលើលទ្ធផលនៃការអនុវត្តថវិកាទាំងខាងមន្ទីរ គម្រោង និងអង្គការ ។ ការអនុវត្តបែបនេះជាជំហានមួយ សំដៅពង្រឹងគណនេយ្យភាពខ្សែទទឹង និងគណនេយ្យភាពរួមគ្នា ប៉ុន្តែក្នុងវិស័យផ្សេងៗទៀតមិនទាន់មានធ្វើច្រើនទេ (Pak 2009) ។

ដើម្បីសម្របតាម ផែនការជាតិសម្រាប់រយៈពេល ១០ ឆ្នាំ ដៃគូអភិវឌ្ឍន៍សំខាន់ៗ បានចាប់ផ្តើមធ្វើការសម្រួលរបៀបអនុវត្តគម្រោងរបស់ខ្លួន សំដៅបង្កើតឱ្យមានគណនេយ្យភាពទៅវិញទៅមកជាមួយរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ក្នុងនេះ ដៃគូអភិវឌ្ឍន៍ត្រូវសហការច្រើនជាងមុន ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ (គណនេយ្យភាពខ្សែទទឹង) ហើយក្នុងពេលជាមួយគ្នាជួយពង្រឹងសមត្ថភាពរបស់រដ្ឋបាលទាំងនោះ ដើម្បីឱ្យពួកគេអាចឆ្លើយតបបានល្អទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ (គណនេយ្យភាពចុះក្រោម) ។ ឧទាហរណ៍ ថ្មីៗនេះ ធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើការសិក្សាលើគម្រោងរបស់ខ្លួន ដើម្បីកំណត់ថា តើសកម្មភាពណាត្រូវបន្តសហការដោយផ្ទាល់ជាមួយថ្នាក់ជាតិ និងសកម្មភាពណាត្រូវប្តូរមកសហការជាមួយថ្នាក់ក្រោមជាតិវិញ ។

## ៥. គណនេយ្យភាព និងបរិវារកិច្ច

ការពិភាក្សាខាងលើ ពាក់ព័ន្ធនឹងគណនេយ្យភាពដោយគោរពតាមច្បាប់ និងវិធានជាផ្លូវការរបស់រដ្ឋាភិបាល និងរបស់ដៃគូអភិវឌ្ឍន៍ ។ ប៉ុន្តែគណនេយ្យភាពពុំមែនសុទ្ធតែកំណត់តាមអ្វីដែលមានចែងជាផ្លូវការនោះទេ ។ នៅពេលច្បាប់នៅខ្វះចន្លោះ ឬមិនទាន់បានអនុវត្ត កត្តាមានឥទ្ធិពលខ្លាំង គឺ ទំនាក់ទំនងរវាងបុគ្គលតាមខ្សែ តាមខ្នងដែលគេហៅថា បរិវារកិច្ច ។

ការប្រាស្រ័យទាក់ទង តាមការស្គាល់គ្នាតាមខ្សែ តាមខ្នងជាទង្វើសាមញ្ញមួយក្នុងគ្រប់សង្គម ។ តាមការប្រាស្រ័យទាក់ទងនេះ គណនេយ្យភាពមួយបានកកើតឡើងរវាងអ្នកដែលជាខ្នង និងអ្នកដែលដើរតាម ។ គណនេយ្យភាពនេះ គ្មានការកំណត់តាមច្បាប់ ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សរអ្វីឡើយ ដោយវាឈរលើការទុកចិត្ត និងការផ្តល់ប្រយោជន៍ទៅវិញទៅមករវាងបុគ្គលទាំងពីរ ។ ក្នុងនេះ អ្នកតូច ត្រូវមានគណនេយ្យភាពចំពោះអ្នកធំជាងខ្លួន ដោយបង្ហាញពីភាពស្មោះត្រង់ និងការបម្រើ ឬផ្តល់ជាប្រយោជន៍អ្វីមួយ ។ រីឯអ្នកធំវិញ ទោះគ្មាននិយាយ ឬចែងជាលាយលក្ខណ៍អក្សរអ្វី ក៏ត្រូវមានគណនេយ្យភាពចំពោះអ្នកតូចជាងខ្លួន ដោយត្រូវផ្តល់ការគាំពារ និងផលប្រយោជន៍មួយចំនួន ដែលភាគីទាំងសងខាងរំពឹងទុក ។ ដោយសារគ្មានអ្វីកំណត់ជាលាយលក្ខណ៍អក្សរ ការរំពឹង និងទំនាក់ទំនងរវាងអ្នកធំ និងអ្នកតូច នៅក្នុងបរិវារកិច្ច ច្រើនអាស្រ័យតាមទម្លាប់ដែលមានពីមុនមក ឬតាមកត្តាវប្បធម៌ និងប្រពៃណីដែលមានស្រាប់ (Pak *et al.* 2007) ។

នៅប្រទេសកំពុងអភិវឌ្ឍន៍ បរិវារកិច្ចជ្រៀតចូលយ៉ាងជ្រៅទៅក្នុងការងាររដ្ឋបាលសាធារណៈ ។ ក្នុងស្ថានភាពនេះ គណនេយ្យភាពតាមផ្លូវច្បាប់ វាចូលលាយឡំជាមួយនឹងគណនេយ្យភាពតាមបែបបរិវារកិច្ច ។ បរិវារកិច្ចទីនេះ អាចកើតមានរវាងមនុស្សតែពីរបីនាក់ ឬក៏មនុស្សច្រើនរួមគ្នា ដោយក្នុងនោះ បុគ្គលម្នាក់អាចជាខ្នងរបស់មនុស្សរាប់សិបនាក់ដែលនៅក្រោមគាត់ និងដែលជាអ្នកដើរតាមនិងបម្រើផលប្រយោជន៍ឲ្យគាត់ និងយករូបគាត់ធ្វើជាខ្នងរបស់ពួកគេ ។ ទំនាក់ទំនងនេះប្រទាក់ក្រឡាគ្នាបង្កើតជាប្រព័ន្ធអាថ៌កំបាំងមួយ មានទម្រង់ដូចជាពីរ៉ាមីតភ្ជាប់បន្តគ្នាតាំងពីអ្នកមានអំណាចខ្លាំងបំផុត រហូតដល់អ្នកតូចតាចនៅខាងក្រោម ។ មនុស្សនៅក្នុងប្រព័ន្ធនេះ បែងចែកជាក្រុម ជាបក្សពួក ពេលខ្លះសហការគ្នា ពេលខ្លះទៀតប្រកួតប្រជែងគ្នា ដើម្បីកាន់កាប់ និងទាញយកប្រយោជន៍ពីរដ្ឋ ឬពីវិស័យសាធារណៈ ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh
Website: http://www.cdri.org.kh

ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈនៅកម្ពុជាក៏មានលាយឡំនឹងបរិវារកិច្ចខ្លះដែរ ។ បរិវារកិច្ចនេះ ក្នុងករណីខ្លះបានជួយបំពេញដល់កង្វះខាត នៅក្នុងប្រព័ន្ធផ្លូវការរបស់រដ្ឋ ។ ឧទាហរណ៍ ទោះបីតាមផ្លូវរដ្ឋ អភិបាលខេត្តមិនសូវមានទំនាក់ទំនងច្រើនជាមួយមន្ទីរ និងការិយាល័យខ្សែបណ្តោយក្តី ប៉ុន្តែតាមខ្សែគណបក្ស និងតាមផ្លូវបុគ្គល មន្ត្រីទាំងនេះមានការប្រាស្រ័យទាក់ទងគ្នាច្រើន ។ ចំណុចមិនល្អនៃការប្រាស្រ័យទាក់ទងបែបនេះ គឺភាគច្រើនវាមិនបានជួយឱ្យមានគណនេយ្យភាពចំពោះអនុលោមភាព និងលទ្ធផល ឬ គណនេយ្យភាពចំពោះប្រជាជន ដូចបានរៀបរាប់ខាងលើឡើយ ។ ផ្ទុយទៅវិញ វាបានប៉ះពាល់ដល់គណនេយ្យភាព ក្នុងការអនុវត្តច្បាប់គ្រប់គ្រងចំណាយព្រោះពេលខ្លះ ការចរចាថវិកា ការទម្លាក់ថវិកា ការស្នើសុំដកចំណាយ ការចុះត្រួតពិនិត្យ និងសវនកម្ម ។ល។ ត្រូវពឹងផ្អែកលើការឃោគយល់រវាងបុគ្គល ឬបក្សពួក ជាជាងតាមការកំណត់ក្នុងច្បាប់ (Pak and Craig 2008) ។

ក្នុងពេលកន្លងមក រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានខិតខំកែទម្រង់លើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយរំពឹងថា នៅពេលប្រព័ន្ធផ្លូវការរឹងមាំ បញ្ហាឥទ្ធិពលបុគ្គល និងបរិវារកិច្ច នឹងថយចុះ ។ ការខិតខំនេះ បានចេញជាផ្លែផ្កាមួយចំនួន ដូចជា កំណើនចំណូលក្នុងថវិការដ្ឋចាប់ពីឆ្នាំ ២០០៧ មក ការផ្ទេរថវិកាបានលឿនជាងមុនទៅឱ្យថ្នាក់មូលដ្ឋានជាដើម ប៉ុន្តែដោយសារបរិវារកិច្ចនៅកម្ពុជា បានចាក់ឫសជ្រៅនៅក្នុងសង្គម និងប្រទាក់ក្រឡាជាមួយកត្តានយោបាយ និងកត្តាប្រវត្តិសាស្ត្រមួយចំនួន ដូច្នេះការអនុវត្តកំណែទម្រង់ចំណាយសាធារណៈ មិនអាចដោះស្រាយបានក្នុងរយៈពេលខ្លីឡើយ ។ ម្យ៉ាងទៀត ការកែប្រែទម្លាប់នេះ ត្រូវមានការចូលរួមមិនត្រឹមពីអ្នកនយោបាយ និងមន្ត្រីរាជការស៊ីវិលប៉ុណ្ណោះទេ ប៉ុន្តែពីសង្គមស៊ីវិល និងមហាជនទូទៅផងដែរ ។

## ៦. សេចក្តីសន្និដ្ឋាន

ក្នុងការពិភាក្សាអំពីពាក្យ គណនេយ្យភាព នៅក្នុងបរិបទនៃការគ្រប់គ្រងចំណាយនៅថ្នាក់ក្រោមជាតិ៖ ទី១ គួរបញ្ជាក់ឱ្យច្បាស់អំពីគណនេយ្យភាពរវាងអ្នកណា? ទៅអ្នកណា? ទៅលើដែនភារកិច្ចអ្វី? និងមានប្រព័ន្ធគ្រប់គ្រងអ្វីខ្លះសម្រាប់ធានាឱ្យមានគណនេយ្យភាព? ការបញ្ជាក់ច្បាស់នេះ នឹងជួយកាត់បន្ថយការយល់ច្រឡំក្នុងការពិភាក្សា ។ ទី២ គួរស្វែងយល់បន្ថែមពីប្រព័ន្ធគ្រប់គ្រងចំណាយនានាដែលកំពុងដំណើរការនៅថ្នាក់ក្រោមជាតិ ។ គួរចោទសួរថា តើប្រព័ន្ធនីមួយៗនាំឱ្យមានគណនេយ្យភាពប្រភេទណា? ជាគណនេយ្យភាពចំពោះអនុលោមភាព ឬលទ្ធផល? ទៅថ្នាក់លើ? ទៅប្រជាជន? តាមខ្សែទទឹង? និងតើគណនេយ្យភាពទាំងនោះ បំពេញឱ្យគ្នា ឬប្រទាំងប្រទើសគ្នាបែបណា?

តាមការរៀបរាប់ខាងលើ គណនេយ្យភាពក្នុងការគ្រប់គ្រងចំណាយនៅថ្នាក់ក្រោមជាតិកម្ពុជា អាចដើរទៅមុខបាន លុះត្រាមានការរីកចម្រើនទៅមុខ និងការសម្របសម្រួលគ្នារវាងកំណែទម្រង់៣គឺ៖ (១) កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២) កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង (៣) កំណែទម្រង់ក្នុងការសម្របសម្រួលជំនួយអន្តរជាតិ ។ កំណែទម្រង់ទាំងនេះ ពាក់ព័ន្ធទាំងការងារបច្ចេកទេសផង និងការងារនយោបាយផង ហើយក្នុងនោះ បរិវារកិច្ច គឺជាកត្តាមួយយ៉ាងសំខាន់ដែលគួរស្វែងយល់បន្ថែម និងជម្នះ ។

## ឯកសារយោងសំខាន់ៗ

National Treasury (2010), *Announcement on the meeting from 21-23 October*, Phnom Penh, Cambodia
NCDD (2008), *2008 Annual Work Plan and Budget*, Phnom Penh, Cambodia
Pak, K (2009), Mapping Budget Information in Health, NGO forum on Cambodia, Phnom Penh, Cambodia
Pak, K (2010), *Assessment of Actual and Potential Commune and Sangkat Council Functions (unpublished field report)*, National League of the Communes/Sangkats and GTZ, Phnom Penh, Cambodia
Pak, K. & D. Craig (2008), *Accountability and Public Expenditure Management in Decentralised Cambodia*, Working Paper Series 38, CDRI, Phnom Penh, Cambodia
Pak, K., V. Horng, N. Eng, S. Ann, S. Kim, J. Knowles & D. Craig (2007), *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review*, Working Paper No. 34, CDRI , Phnom Penh, Cambodia
PFMRP Secretariat (2009), *Progress Report on Public Financial Management Reform Program*, MEF, Cambodia
PSDD (2009), *2009 Annual Work Plan and Budget*, Phnom Penh, Cambodia
RGC (2009), *Proposed budget for 2010*, Phnom Penh, Cambodia
RGC (2010), *Aid Effectiveness Report*, Phnom Penh, Cambodia
World Bank (2004), *Making Services Work for Poor People*, World Development Report
World Bank (2005), *East Asia Decentralises: Making Local Government Work*, Washington DC